01298971



# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:48
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: *មិនមែនជាភាគី*-មជ្ឈមណ្ឌលច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀប (CLCL) មហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ Baltimore

ដាក់ជូន: ក្រឡាបញ្ជីការិយាល័យសហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦

## <u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សារណាមិនមែនជាភាគីដាក់ដោយមជ្ឈមណ្ឌលច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀប មហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ Baltimore ស្តីពីនីត្យានុកូលភាពនៃការដាក់គោលដៅវាយប្រហារយោធាខ្លួនឯង

---

<u>**ដាក់ដោយ៖**</u>

**មិនមែនជាភាគី**

មជ្ឈមណ្ឌលច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀប មហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ Baltimore

<u>**ផ្ញើជូន៖**</u>

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម

Michael G. KARNAVAS

**ការិយាល័យរដ្ឋបាល**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ហុង គឹមសួន

គឹម ម៉េងឃី

ច សុវណ្ណារី

សំ សុគង់

ហុង គឹមសួន

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

សំ សុគង់

ទី ស្រីនណា

វ៉េន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES
Françoise GAUTRY
Isabelle DURAND
Nicole DUMAS

# សេចក្ដីផ្ដើម

1. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស)នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញផ្សាយសេចក្ដីអំពាវនាវឱ្យមានការដាក់សារណាពីអ្នកដែលមិនមានជាភាគី ដោយអនុវត្តសិទ្ធិអំណាចរបស់ការិយាល័យតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ គោលបំណងនៃសេចក្ដីអំពាវនាវនេះគឺដើម្បីសម្រេចលើច្បាប់ទម្លាប់អន្តរជាតិ ស្ដីពីបញ្ហាចោទថាតើការវាយប្រហាររបស់រដ្ឋ ឬ អង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ*ផ្ទាល់ខ្លួន* អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល។ បន្ថែមពីលើនេះទៀត ក៏ចោទសួរថាតើការវាយប្រហារបែបនេះបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬអត់ប្រសិនបើសកម្មភាពទាំងនេះមានលក្ខណៈជាទូទៅ និងជាប្រព័ន្ធ។

2. មិនមានការស្នើសុំការឯកភាពពីភាគីនៅក្នុងសំណុំរឿងទេមុនពេលដាក់ឯកសារ។ មជ្ឈមណ្ឌលច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀប(CLCL) នៅមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ Baltimore បានដាក់សារណាមិនមែនជាភាគីនេះ ជាការឆ្លើយតបផ្ទាល់ទៅនឹងសេចក្ដីអំពាវនាវរបស់ ក.ស.ច.ស។

3. CLCL លើកកម្ពស់ការសិក្សា និងការស្វែងយល់អំពីច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀប ព្រមទាំងស្ថាប័ននយោបាយ និងសេដ្ឋកិច្ចដែលគាំទ្រសណ្ដាប់ធ្នាប់ច្បាប់អន្តរជាតិ។ បង្កើតឡើងនៅឆ្នាំ ១៩៩៤ CLCL គឺជាអ្នកឧបត្ថម្ភគាំទ្រការស្រាវជ្រាវ ការបោះពុម្ពផ្សាយ ការបង្រៀន និងការផ្សព្វផ្សាយចំណេះដឹងអំពីបញ្ហាច្បាប់អន្តរជាតិ ដោយយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិមនុស្ស ប្រជាធិបតេយ្យ កម្មសិទ្ធិបញ្ញា និងប្រតិបត្តិការអាជីវកម្មអន្តរជាតិ។ គម្រោងសិទ្ធិមនុស្ស (Human Rights Inititaive) លើកកម្ពស់ការសិក្សា ការស្វែងយល់ និងការអនុវត្តសិទ្ធិមនុស្សជាសកល ដូចមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀងថ្នាក់តំបន់ និងច្បាប់ទម្លាប់អន្តរជាតិ។ គម្រោងនេះពិចារណាលើលក្ខណៈ និងមូលដ្ឋាននៃសិទ្ធិមនុស្សជាសកល និងសេរីភាពជាសារវ័ន្ត ហើយជំរុញឱ្យសិទ្ធិ និងសេរីភាពទាំងនេះទទួលបានដោយស្មើភាពគ្នាសម្រាប់ជនគ្រប់រូប និងប្រជាជាតិទាំងអស់។ គម្រោងសិទ្ធិមនុស្ស ក៏ធ្វើការលើកកម្ពស់ការផ្សព្វផ្សាយមនុស្សធម៌អន្តរជាតិ និងលើកកម្ពស់នីតិរដ្ឋតាមរយៈការស្រាវជ្រាវច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

4. មេធាវី និងអ្នកសិក្សាស្រាវជ្រាវគ្រប់គ្រងសារណានេះគឺ Catherine Moore អ្នកសម្របសម្រួលកម្មវិធីច្បាប់អន្តរជាតិ និងជាសាស្ត្រាចារ្យនៅ CLCL ។ សហការីនៅ CLCL ឈ្មោះ Shane Bag well, Christian Kim, John Rizos និង Kia Roberts-Warren បានជួយរៀបចំសារណានេះ។

## សង្ខេប

5. ច្បាប់ទម្លាប់អន្តរជាតិ ទាំងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ទាំងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ គាំទ្រការយល់ឃើញដែលថា ជីវិតមនុស្សគប្បីត្រូវគោរព និងការពារ។ ទោះបីជានៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មិនមានច្បាប់សន្ធិសញ្ញាណាដែលហាមឃាត់យ៉ាងច្បាស់លាស់មិនឲ្យដាក់គោលដៅវាយប្រហារយោធាខ្លួនឯងក៏ដោយ ក៏ច្បាប់ទម្លាប់អន្តរជាតិនៅពេលនោះ ផ្តល់កិច្ចការពារដ៏ចាំបាច់ឲ្យបុគ្គលយោធាបែបនោះដែរ។

6. ច្បាប់មនុស្សធម៌អន្តរជាតិ ពិតជាចែងអំពីការសម្លាប់មនុស្សនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ប៉ុន្តែ ច្បាប់នេះមិនចែងថា ការសម្លាប់បែបនេះមានគោលដៅសំដៅលើប្រជាជនខ្លួនឯងនោះទេ ទោះជាថា អ្នកដែលជាមុខសញ្ញាគោលដៅទាំងនោះគឺជាសមាជិកយោធា ក៏ដោយ និងជាពិសេស ទោះជាថា ការសម្លាប់ទាំងនោះបានធ្វើឡើងដោយគ្មានសាលក្រមពីតុលាការណាមួយដែលគេបានបង្កើតឡើងតាមទម្លាប់ធម្មតាក៏ដោយ។

7. ការវិភាគនេះប្រើប្រាស់មូលដ្ឋានពីរនៃច្បាប់មនុស្សធម៌អន្តរជាតិ គឺគោលការណ៍ភាពខុសគ្នា និងគោលការណ៍មនុស្សជាតិ ព្រមទាំងសិទ្ធិរស់រានមានជីវិតដែលមិនអាចធ្វើបដិប្បញ្ញត្តិបាននៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

## ក. តាមច្បាប់មនុស្សធម៌អន្តរជាតិ ការវាយប្រហាររបស់រដ្ឋ ឬអង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធខ្លួនឯង អាចខុសច្បាប់

1. ការដាក់គោលដៅវាយប្រហារទាហានខ្លួនឯងរបស់ប្រទេសណាមួយ មិនមែនសុទ្ធតែជាការរំលោភច្បាប់មនុស្សធម៌អន្តរជាតិទេ ដរាបណាមានការដាក់បម្រាមមួយចំនួនលើសកម្មភាពបែបនេះ។ ច្បាប់ទម្លាប់អន្តរជាតិ បានវិវត្តក្នុងរយៈពេលប៉ុន្មានសតវត្សរ៍ចុងក្រោយនេះដើម្បីកំណត់ពីវិធានស្តីពីការប្រយុទ្ធគ្នារវាងប្រទេសនានា ចំណែកឯ បញ្ញត្តិថ្នាក់ជាតិវិញ បានកំណត់ពីអ្វីដែលចាំបាច់សម្រាប់វិន័យផ្ទៃក្នុង។ ហេតុនេះ យើងប្រើប្រាស់ការបញ្ចូលគ្នាជាពិសេសរវាងវិធាន និងបញ្ញត្តិ

ទាំងពីរនេះ ដោយសារវិសាលភាពធ្ងន់ធ្ងរនៃការដាក់វិន័យ ចំពោះទាហានដែលទទួលរងការដាក់វិន័យ និងកម្រិតធ្ងន់ធ្ងរនៃការដាក់ទណ្ឌកម្ម ព្រមទាំងអង្គហេតុដែលថា ទាហាន គឺជាជនជាតិកម្ពុជា ហើយជាគោលដៅវាយប្រហារនៅក្នុងប្រទេសកម្ពុជា។ **សកម្មភាពដែលចុងចោទបានអនុវត្ត គឺហួសឆ្ងាយពីអ្វីដែលអាចចាត់ទុកថាជាវិន័យផ្ទៃក្នុង ហើយរំលោភបំពានច្បាប់មនុស្សធម៌អន្តរជាតិ និងបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ហេតុនេះ មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អាចអនុវត្តបាន។**

2. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី (ICTY) បានសម្រេចនៅក្នុងរឿងក្តី *Tadić* ថា ជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ គឺជាកម្មវត្ថុនៃមាត្រា ៣ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ (មាត្រា ៣ រួម) ពិធីសារបន្ថែម II ព្រមទាំងច្បាប់ទម្លាប់នៃច្បាប់មនុស្សធម៌អន្តរជាតិ រាប់បញ្ចូលទាំងគោលការណ៍ភាពខុសគ្នា សមាមាត្រ ភាពចាំបាច់ផ្នែកយោធា និងការហាមឃាត់មិនឲ្យទទួលរងការឈឺចាប់មិនចាំបាច់[1]។ ភាពខុសគ្នា និងគោលការណ៍មនុស្សជាតិ គឺជា "គោលការណ៍មូលដ្ឋាន"ពីរនៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលអាចអនុវត្តបានច្រើនបំផុតនៅក្នុងករណីនេះ[2]។

## ភាពខុសគ្នា

3. ជាដំបូង យើងក្រឡេកមើលបញ្ហាភាពខុសគ្នា ពីព្រោះថា យោធានៅជួរកងទ័ពបដិវត្តន៍កម្ពុជា (ក.ប.ក) គឺជាគោលដៅមុខសញ្ញារបស់សមាសភាពនយោបាយនៃរដ្ឋាភិបាលខ្លួនឯង ហើយពួកគេស្ថិតនៅក្នុងកណ្តាប់ដៃរបស់ជនទាំងឡាយនៅក្នុងកងកម្លាំងប្រដាប់អាវុធដែលយោធាទាំងនោះបម្រើការងារ។

4. នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ (ទាំងអន្តរជាតិ ទាំងមិនមែនអន្តរជាតិ) រដ្ឋត្រូវតែតម្រង់គោលដៅវាយប្រហារតែលើវត្ថុ និងជនដែលជាគោលដៅយោធាសមស្របតែប៉ុណ្ណោះ។ គោលការណ៍ ភាពខុសគ្នាគឺជាស្នូលនៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលការវាយប្រហារមិនត្រូវសំដៅលើវត្ថុរបស់ជនស៊ីវិល ឬជនដែលត្រូវការពារ រួមមាន ប្រជាជនស៊ីវិល អ្នករបួស អ្នកជំងឺ និងឈ្លើយសឹក។ យុទ្ធជនរបស់កម្លាំងសត្រូវ ជានិច្ចកាលត្រូវចាត់ទុកថាជាគោលដៅយោធាសមស្រប

---

[1] Major Ian Corey *មាគ៌ាត្រឹមត្រូវរវាងគោលនយោបាយ ជាមួយនឹងទំនៀមទម្លាប់៖ រដ្ឋអាជ្ញាតទល់នឹង Tadic និងច្បាប់ទម្លាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធផ្ទៃក្នុង,* 166 Mil. L. Rev ទំព័រ ១៤៥ និង ១៥២ (ឆ្នាំ ២០០០)។

[2] *នីត្យានុកូលភាពនៃការគំរាមកំហែង ឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរ* មតិយោបល់ប្រឹក្សា I.C.J 226 ទំព័រ ៧៨ (ឆ្នាំ១៩៩៦)។

ប្រសិនបើពួកគេមិនបាត់បង់សមត្ថភាពប្រយុទ្ធ (ឧ. ជាអ្នករបួស អ្នកជំងឺ ឈ្លើយសឹក បុគ្គលិកពេទ្យ ឬទាហានមិនសកម្ម)។

5. ការវាយប្រហារត្រូវសំដៅផងដែរលើគោលដៅយោធា។ ការវាយប្រហារត្រូវកម្រិតនៅត្រឹមលើវត្ថុបំណងដែលគោលបំណងនៃការវាយប្រហារ ឬក៏ការប្រើប្រាស់ការវាយប្រហារនេះបានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់សកម្មភាពយោធា ហើយការបំផ្លាញទាំងស្រុង ឬផ្នែកខ្លះផ្តល់ប្រយោជន៍ច្បាស់លាស់[3]។ គួរឲ្យចាប់អារម្មណ៍គឺថា បុព្វកថានៃសេចក្តីប្រកាស St. Peterburg ឆ្នាំ ១៨៦៨ បញ្ជាក់ថា៖

> “វត្ថុបំណងសមស្របតែមួយគត់ដែលរដ្ឋនានា គប្បីព្យាយាមសម្រេចក្នុងអំឡុងពេលសង្គ្រាម គឺត្រូវធ្វើឲ្យកម្លាំងយោធារបស់សត្រូវទន់ខ្សោយ”[4]។

គេអាចជំទាស់បានថា ការដាក់គោលដៅវាយប្រហារកងកម្លាំងប្រដាប់អាវុធខ្លួនឯងរបស់រដ្ឋណាមួយ នឹងមិន“ធ្វើឲ្យកម្លាំងយោធារបស់សត្រូវទន់ខ្សោយ”ឡើយ ហេតុនេះ គោលដៅនេះមិនត្រូវចាត់ទុកថាជាគោលដៅសមស្របតាមបទដ្ឋាននេះឡើយ។ នៅពេលដែលរដ្ឋណាមួយសម្លាប់ទាហានខ្លួនឯង គឺធ្វើឲ្យកម្លាំងប្រដាប់អាវុធខ្លួនឯងទន់ខ្សោយ មិនមែនធ្វើកម្លាំងប្រដាប់អាវុធសត្រូវទន់ខ្សោយទេ ដោយបំផ្លិចបំផ្លាញកងទ័ពខ្លួនឯងទៅវិញ។

6. ដូចដែល ក.ស.ច.ស បានបញ្ជាក់យ៉ាងត្រឹមត្រូវដែរ ភាពខុសគ្នារវាងយោធា និងជនស៊ីវិល គឺធម្មតាសំដៅលើកម្លាំងប្រឆាំង។ ប៉ុន្តែ តាមគោលបំណងរបស់យើង យើងត្រូវតែពិចារណាលើមូលហេតុដែលប្រើប្រាស់កម្លាំង។ វិន័យផ្ទៃក្នុង និងសន្តិសុខ គឺជាមូលដ្ឋានគ្រឹះដើម្បីឲ្យកម្លាំង

---

[3] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ(គ.ក.ក.អ) *ពិធីសារបន្ថែមលើអនុញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងទាក់ទងនឹងការការពារជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធអន្តរជាតិ*(ពិធីសារបន្ថែម I) ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧, 1125 U.N.T.S.3 មាត្រា ៥២(២)។ សូមមើលផងដែរ *សេចក្តីព្រាងវិធានសម្រាប់ដែនកំណត់នៃគ្រោះថ្នាក់ដែលប្រជាជនស៊ីវិលទទួលរងក្នុងពេលសង្គ្រាម* គ.ក.ក.អ (ឆ្នាំ ១៩៥៦) មាត្រា ៧ (“គោលដៅតែមួយគត់នៅក្នុងប្រភេទគោលដៅវាយប្រហារដែលតាមលក្ខណៈសំខាន់ត្រូវគេទទួលស្គាល់ជាទូទៅថាមានសារៈសំខាន់ផ្នែកយោធានោះ អាចត្រូវចាត់ទុកថាជាគោលដៅយោធា...។ ប៉ុន្តែ ទោះជាថា គោលដៅនេះស្ថិតនៅក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទគោលដៅវាយប្រហារយ៉ាងណាក៏ដោយ ក៏គោលដៅនេះមិនអាចចាត់ទុកថាជាគោលដៅយោធាបានដែរក្នុងករណីដែលការបំផ្លាញគោលដៅនេះទាំងស្រុង ឬផ្នែកខ្លះ...មិនបានផ្តល់ប្រយោជន៍ផ្នែកយោធា”)។

[4] *សេចក្តីប្រកាសលុបចោលការប្រើប្រាស់ឧបករណ៍បាញ់គ្រឿងផ្ទុះមួយចំនួនក្នុងពេលសង្គ្រាម* Saint Petersburg(ឆ្នាំ ១៨៦៨)។

ប្រយុទ្ធមួយមានប្រសិទ្ធភាព ហើយរដ្ឋាភិបាល មានសេរីភាពយ៉ាងច្រើនក្នុងការជ្រើសរើសរបៀប ដែលខ្លួន អនុវត្តច្បាប់/បទបញ្ជានៅក្នុងជួរកម្លាំងប្រដាប់អាវុធ រហូតដល់ថ្នាក់អនុញ្ញាតឱ្យ ប្រហារជីវិតក្នុងករណីដែលកំសាក ធ្វើពុតជាឈឺ ការបំពេញការងារមិនល្អ ក្បត់ជាតិ ។ល។[5] មាន មូលហេតុយុត្តិកម្មដើម្បីសម្លាប់ទាហានដែលបានគំរាមកំហែងដល់សន្តិសុខជាតិ ឬគំរាមកំហែង ដល់លទ្ធភាពដែលនឹងអាចទទួលបានជ័យជំនះ ដោយផ្អែកលើការបំពេញការងារ ឬអត្តចរិត មិន មែនផ្អែកលើសមាសភាពពូជសាសន៍ ជាតិពិន្ទុ ឬជំនឿនយោបាយ ឬឥន្ទ្រះនយោបាយឡើយ។

7. ជាចុងក្រោយ យោធាដែលខ្មែរក្រហមបានសម្លាប់ អាចមិនមានឋានៈជាអ្នកបាត់បង់សមត្ថភាព ប្រយុទ្ធតាមទំនៀមទម្លាប់ធម្មតាទេ ប៉ុន្តែមានភាពស្រដៀងគ្នានេះច្រើន។ យោធាទាំងនេះមិនបាន ប្រឆាំងនឹងរបបខ្លួនឯង ដែលត្រូវសម្លាប់ពួកគាត់ដោយសារមូលហេតុប្រឆាំងបែបនេះ ហើយពួក គាត់ក៏មិនបានប៉ុនប៉ងប្រយុទ្ធ ឬបង្កើតការបះបោលប្រឆាំងនឹងខ្មែរក្រហមដែរ។ ពួកគាត់គឺជាអ្នក នៅក្រោមបង្គាប់តាមការសម្រេចរបស់របបនេះ ដូចជា ឈ្លើយសឹក ដែលស្ថិតនៅក្រោមការ សម្រេចរបស់អ្នកដែលចាប់ខ្លួនពួកគាត់ដែរ។ ជាងនេះទៀត យោធាដែលគេសម្លាប់គឺមានសមាស ភាពពូជសាសន៍ផ្សេងៗគ្នា។ ក្រោយសង្គ្រាមស៊ីវិល ពួកគាត់បានក្លាយជាសមាជិកនៃកងកម្លាំង ប្រដាប់អាវុធរបស់ខ្មែរក្រហមនៅពេលដែលរបបនេះចាប់ផ្តើមគ្រប់គ្រងរដ្ឋ ហេតុនេះពួកគាត់ "ទទួលដំណែល"ជាកងទ័ព ដូច្នេះធ្វើឱ្យយោធាទាំងនេះកាន់តែក្លាយជាឈ្លើយសឹកទៀត។

8. ទោះបីជាទាហាន មានភាពខុសគ្នា និងនៅដាច់ដោយឡែកពីជនស៊ីវិលបើគិតគ្រប់យ៉ាងអំពីច្បាប់ អន្តរជាតិយ៉ាងណាក៏ដោយ ក៏ទំហំ និងកម្រិតធ្ងន់ធ្ងរនៃការដាក់វិន័យមកលើ ក.ប.ក នៅក្នុងករណី នេះ ជាបញ្ហាគោលការណ៍ អាចជម្នះលើដែនកំណត់នៃភាពខុសគ្នាទាំងនេះបានដែរ។

## គោលការណ៍មនុស្សជាតិ

9. ទីពីរ យើងពិចារណាលើទំនៀមទម្លាប់នៃគោលការណ៍មនុស្សជាតិនៅក្នុងច្បាប់មនុស្សធម៌អន្តរ ជាតិ។ ហេតុនេះ ពិសេសជាងនេះទៀតគឺថា ទំហំនៃការដាក់វិន័យមកលើសមាជិក ក.ប.ក បង្កើត បានជាការឈឺចាប់មួយដែលមិនចាំបាច់។ **ការសម្លាប់ ការធ្វើទារុណកម្ម ការបង្អត់អាហារ និង**

---

[5] *សូមមើលឧទាហរណ៍* មាត្រា ៩០ ក្រមសីលធម៌រួមស្តីពីយុត្តិធម៌យោធា៖ ការវាយប្រហារ ឬការមិនគោរពមន្ត្រីថ្នាក់លើដោយចេតនា រៀបចំជាក្រម 10 U.S.C 890។

**ពលកម្មដោយបង្ខំដែលបានអនុវត្តមកលើឃោធា គឺមិនបានបម្រើឲ្យគោលបំណងយោធាណាមួយដែលសមស្របទេ។**

10. មាត្រា ៣ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ ការពារ "ជនដែលមិនបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពអរិភាព រួមមាន **សមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធ** និងជនដែលស្ថិតក្នុងស្ថានភាពបាត់បង់សមត្ថភាពប្រយុទ្ធដោយសាជំងឺ របួស **ការឃុំខ្លួន ឬមូលហេតុណាផ្សេងទៀត**" [6]។ មានលក្ខខណ្ឌតម្រូវមួយថា ជនទាំងនេះ ត្រូវ"ទទួលបានការប្រព្រឹត្តិដោយមនុស្សធម៌ ដោយគ្មានការបែងចែកប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សាសនា ឬជំនឿ ភេទ កំណើត ឬទ្រព្យសម្បត្តិ ឬលក្ខណៈវិនិច្ឆ័យស្រដៀងគ្នាណាផ្សេងទៀត" [7]។ មាត្រា ៣ រួម មិនបញ្ជាក់ថា "សមាជិកនៃកងកម្លាំងប្រដាប់អាវុធ" ត្រូវតែជាសមាជិកនៃកងកម្លាំងសត្រូវទេ ប៉ុន្តែ គឺជា"**ជន ដែលបានទម្លាក់អាវុធ**"[8]។ អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក បានសម្រេចថា សមាជិកនៃអង្គការប្រដាប់អាវុធ ទោះបីជាថាបាត់បង់សមត្ថភាពប្រយុទ្ធក៏ដោយ ក៏មិនមានលក្ខណៈសម្បត្តិជាជនស៊ីវិលដែរតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[9] ប៉ុន្តែ ជនដែលបានទម្លាក់អាវុធ គួរត្រូវចាត់ទុកថាបានបាត់បង់សមត្ថភាពប្រយុទ្ធ គឺដូចគ្នានឹងឈ្លើយសឹក ដែលត្រូវចាត់ទុកថាបានបាត់បង់សមត្ថភាពប្រយុទ្ធដែរ។

11. មាត្រា ៣ រួម ក៏ហាមឃាត់មិនឲ្យ "ដាក់ទោស និងអនុវត្តការប្រហារជីវិត បើគ្មានសាលក្រមជាមុនដែលប្រកាសឡើងដោយតុលាការមួយដែលបានបង្កើតឡើងតាមទម្លាប់ធម្មតា ដោយផ្តល់ការធានាតាមផ្លូវតុលាការទាំងអស់ដែលប្រជាជាតិមានអរិយធម៌ទទួលស្គាល់ថាមិនអាចខ្វះបាន"[10]។

---

[6] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ(គ.ក.ក.អ) *អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងនឹងការប្រព្រឹត្តិមកលើឈ្លើយសឹក* ("អនុសញ្ញាទីក្រុងហ្សឺណែវទី ៣") ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩, 75 U.N.T.S.135 មាត្រា ៣។

[7] ដូចជើងទំព័រខាងលើ។

[8] ដូចជើងទំព័រខាងលើ។

[9] សំណុំរឿង 00២ ឯកសារ E313 *សាលក្រម* ថ្ងៃទី 0៧ ខែ សីហា ឆ្នាំ ២0១៤ កថាខណ្ឌ ១៨៦។ សំណុំរឿង 00១ ឯកសារ E188 *សាលក្រម*។

[10] អនុសញ្ញាទីក្រុងហ្សឺណែវទី ៣ ជើងទំព័រ ៦ ខាងលើ មាត្រា ៣។

ការធានាតាមផ្លូវតុលាការបែបនេះ មិនអាចញូវមិនអនុវត្តបានទេនៅក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ[11]។

**ខ. តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ គោលដៅសម្លាប់សមាជិកណាម្នាក់នៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់រដ្ឋណាមួយ អាចបង្កើតបានជាការរំលោភបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិ នៅពេលដែលការសម្លាប់បែបនេះធ្វើឡើងជាប្រព័ន្ធ ការសម្លាប់បែបនេះអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬជាអំពើប្រល័យពូជសាសន៍**

12. ការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ នៅក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ គឺជាបញ្ហាច្បាប់មួយដែលបានជជែកវែកញែកយ៉ាងខ្លាំង[12]។ ប៉ុន្តែ តាមគោលបំណងនៃសារណានេះ ចាំបាច់ត្រូវបញ្ជាក់ថា ទោះបីជាថា បុគ្គលណាម្នាក់គឺជាសមាជិកយោធា ហើយត្រូវចាត់ទុកថាជាយុទ្ធជននៅក្នុងជម្លោះប្រដាប់អាវុធក៏ដោយ ក៏គាត់នៅតែអាចទទួលបានការការពារតាម ច្បាប់សិទ្ធិមនុស្សអន្តរជាតិដែរ។

## សិទ្ធិរស់រានមានជីវិត

13. សិទ្ធិរស់រានមានជីវិតគឺជាសិទ្ធិមួយជាមូលដ្ឋាន ជាសកលដែលបានប្រកាសនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើន និងជាច្បាប់ទម្លាប់អន្តរជាតិ[13]។ យោងតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR)

---

[11] *សូមមើលឧទាហរណ៍* ពិធីសារបន្ថែម II មាត្រា ៦(២) (បានអនុម័តដោយឯកច្ឆ័ន្ទ)។ ពិធីសារបន្ថែម I មាត្រា ៧៥(៤) (បានអនុម័តដោយឯកច្ឆ័ន្ទ)។

[12] *សូមមើល* ជាទូទៅ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស *ការពារសិទ្ធិមនុស្សតាមច្បាប់អន្តរជាតិនៅក្នុងជម្លោះប្រដាប់អាវុធ* HR/PUB/11/01 (ឆ្នាំ ២0១១)។

[13] មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី ១0 ខែ ធ្នូ ឆ្នាំ ១៩៤៨, 217 A (III) មាត្រា ៣ ("បុគ្គលម្នាក់ៗមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន")។ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, 999 U.N.T.S 171 មាត្រា ៦។ *ធម្មនុញ្ញអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិមនុស្ស* ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៨១ CAB/LEG/67/3 rev. 5, 21 I.L.M 58 (ឆ្នាំ ១៩៨២) មាត្រា ៤។ អង្គការរដ្ឋអាមេរិក *អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស "កតិកាសញ្ញា San Jose កូស្តារីកា"* (B-32) ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៦៩ មាត្រា ៤។ សម្ព័ន្ធរដ្ឋអារ៉ាប់ *ធម្មនុញ្ញអារ៉ាប់ស្តីពីសិទ្ធិមនុស្ស* ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៤ មាត្រា ៥-៨។ ក្រុមប្រឹក្សាអឺរ៉ុប *អនុសញ្ញាអឺរ៉ុបការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចបានធ្វើវិសោធនកម្មដោយពិធីសារលេខ ១១ និង ១៤* ថ្ងៃទី 0៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥0 E.T.S. 5 មាត្រា ២។ *សូមមើលផងដែរ* អង្គការរដ្ឋអាមេរិក គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស សម័យប្រជុំលើកទី

"ជនគ្រប់រូប មានសិទ្ធិមានជីវិតជាប់ពីកំណើត...។ គ្មានជនណាម្នាក់ត្រូវគេប្រហារជីវិតតាមអំពើចិត្តឡើយ"។

គោលបំណងនៃមាត្រានេះក្នុងចំណោមគោលបំណងផ្សេងទៀត គឺដើម្បីបង្ការការជ្រៀតជ្រែករបស់រដ្ឋជាមួយនឹងជីវិតមនុស្ស បង្ការការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងការបាត់ខ្លួនដោយបង្ខំ[14]។

14. មានកាលៈទេសៈមួយចំនួនដែលរដ្ឋអាចធ្វើបដិបញ្ញត្តិមិនគោរពសិទ្ធិរស់រានមានជីវិត។ ឧទាហរណ៍ នៅក្នុងអំឡុងពេលចូលរួមជម្លោះប្រដាប់អាវុធ ការប្រហារជីវិតដែលធ្វើឡើងដោយយុទ្ធជនស្របតាមច្បាប់ប្រឆាំងនឹងសត្រូវបច្ចាមិត្ត ត្រូវចាត់ទុកថាជាការស្របច្បាប់តាមច្បាប់មនុស្សធម៌អន្តរជាតិ។

15. កតិកាសញ្ញា ICCPR មិនកំណត់កាលៈទេសៈឲ្យបានច្បាស់លាស់ទេក្នុងករណីដែលអាជ្ញាធររដ្ឋាភិបាល អាចយកជីវិតជនណាម្នាក់[15]។ ប៉ុន្តែ នៅក្នុងរឿងក្តី *Suares de Guerrero តទល់នឹងកូឡុំប៊ី* គណៈកម្មាធិការសិទ្ធិមនុស្ស បានសម្រេចលើបញ្ហាការប្រើប្រាស់កម្លាំងពិឃាត ស្ថិតនៅក្នុងមាត្រា ៦(១) ដែលធ្វើឲ្យអត្ថន័យសិទ្ធិនេះស្រពិចស្រពិល។ ការសម្លាប់ជីវិតមនុស្ស មិនត្រូវធ្វើឡើងដោយចេតនាឡើយ។ ការសម្លាប់ជីវិតមនុស្សត្រូវតែធ្វើឡើងដោយចាំបាច់ និងមានសមាមាត្រផងដែរ[16]។

16. អាជ្ញាធររដ្ឋាភិបាលអាចសម្លាប់ជីវិតមនុស្សតែក្នុងកាលៈទេសៈមានកម្រិត និងតឹងរឹងដាច់ខាត គឺនៅក្នុងសកម្មភាពអរិភាពស្របច្បាប់ ការប្រើប្រាស់កម្លាំងពិឃាតដែលឃុំឃាំងមនុស្ស និងដាក់មនុស្សឲ្យនៅជាប់ឃុំឃាំង កាលៈទេសៈបង្ក្រាបកុបកម្ម ឬការបះបោល និងពេលវេលាដែលដាក់

---

៨១ របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស រឿងក្តី *ជនរងគ្រោះនាវាសណ្តោង "13 de Marzo" តទល់នឹងគុយបា* របាយការណ៍លេខ ៤៧/៩៦, OR OEA/Ser. L/V/II.95/Doc. 7 វិសោធនកម្ម (ឆ្នាំ ១៩៩៧) ទំព័រ ១៤៦-១៤៧ (គណៈកម្មការនេះបានសម្រេចថា សិទ្ធិរស់រានមានជីវិត គឺជាវិធានអាជ្ញាបញ្ញា)។

[14] គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *ការសម្លាប់តាមអំពើចិត្ត៖ របាយការណ៍របស់អ្នករាយការណ៍ពិសេស* E/CN.4/1983/16 (ឆ្នាំ ១៩៨៣)។

[15] Elizabeth Wicks *អត្ថន័យអំពីជីវិត៖ សេចក្តីថ្លៃថ្នូរ និងសិទ្ធិរស់រានមានជីវិតនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ* 12 Hum. Rts. L. Rev. 199, 203 (ឆ្នាំ ២០១២)។

[16] ដូចជើងទំព័រខាងលើ។ *សូមមើលផងដែរ* គណៈកម្មាធិការសិទ្ធិមនុស្ស របាយការណ៍ផ្សព្វផ្សាយលេខ ៤៥/១៩៧៩៖ កូឡុំប៊ី ៣១/០៣/៨២ , CCPR/C/15/D/45/1979 (យុត្តិសាស្ត្រ) ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៨២។

ទោសប្រហារជីវិត។ នៅពេលដែលរដ្ឋាភិបាលប្រើប្រាស់កម្លាំងពិឃាត ការប្រើប្រាស់នេះត្រូវធ្វើឡើងដោយសមាមាត្រ និងចាំបាច់តាមករណីនីមួយៗ។ ទោសប្រហារជីវិតក្នុងករណីដែលរដ្ឋនៅតែអនុវត្តទោសនេះ អាចយកមកប្រើប្រាស់សម្រាប់តែ"ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ស្របតាមច្បាប់"តែប៉ុណ្ណោះ[17]។

**អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

17. អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ អាចយកមកអនុវត្តទាំងនៅក្នុងពេលសន្តិភាព ទាំងនៅក្នុងពេលជម្លោះប្រដាប់អាវុធ[18]។ ការសម្លាប់ ការបង្កការឈឺចាប់ជាដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញា ការបង្ការមិនឲ្យមានកំណើតទារក ការជម្លៀសកូនក្មេងដោយបង្ខំ និងការបង្កឡើងដោយចេតនានូវការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយកម្មេសបំផ្លិចបំផ្លាញក្រុមទាំងមូល ឬផ្នែកខ្លះនៃសង្គម[19]។ អំពើទាំងនេះត្រូវធ្វើឡើង"ក្នុងបំណងបំផ្លាញទោះទាំងស្រុងក្តី ឬខ្លះៗក្តី"ដល់ប្រជាជាតិមួយ ពូជសាសន៍មួយ ឬក្រុមជាតិពិន្ទុមួយ ឬក្រុមសាសនាមួយ[20]។

18. នៅក្នុងស្ថានភាពកម្ពុជា មិនមានក្រុមជាតិពិន្ទុណាមួយដែលជាគោលដៅទេ ប៉ុន្តែ គេយកគោលដៅលើក្រុមបុគ្គល។ ក្រុមបុគ្គលនេះមានជនដែលបង្ហាញភាពមិនស្មោះត្រង់ ឬបង្ហាញការតស៊ូប្រឆាំងនឹងខ្មែរក្រហម រាប់បញ្ចូលទាំងសមាជិកយោធាផងដែរ។ អង្គហេតុដែលថា បុគ្គលទាំងនេះគឺជាសមាជិកនៃកងកម្លាំងយោធា**ផ្ទាល់ខ្លួន**របស់រដ្ឋ គឺមិនសំខាន់នៅក្នុងបរិបទនេះឡើយ។

19. ទោះបីជាមិនដូចគ្នាទាំងស្រុងក៏ដោយ ក៏នៅក្នុងរឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Krstic* អនុមេបញ្ជាការម្នាក់ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទអំពើប្រល័យពូជសាសន៍[21]។ សំអាងហេតុការពារក្តីរបស់មេបញ្ជាការរូបនេះគឺថា គាត់មិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេ ពីព្រោះថា គាត់បានដាក់គោលដៅមុខសញ្ញាតែលើមនុស្សប្រុសដល់អាយុចូលយោធាតែប៉ុណ្ណោះ ដើម្បីកាត់បន្ថយសត្រូវជាជនជាតិបូស្នៀអ៊ីស្លាម ឲ្យនៅតិចបំផុត។ តុលាការ ICTY បានសម្រេចថា ការដកចេញ

---

[17] អនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប មាត្រា ២។

[18] អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍, 78 U.N.T.S. 277 (ឆ្នាំ ១៩៤៨)។

[19] ដូចជើងទំព័រខាងលើ មាត្រា ២។

[20] ដូចជើងទំព័រខាងលើ។

[21] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Radislav Krstic* អង្គជំនុំជម្រះតុលាការកំពូល រឿងក្តីលេខ IT-98-33-A (ឆ្នាំ ២០០៤)។

មនុស្សប្រុសទាំងនេះគឺជាទម្រង់មួយនៃអំពើប្រល័យពូជសាសន៍ ពីព្រោះថា ប្រជាជននៅសេសសល់ទាំងអស់មិនមានមធ្យោបាយការពារខ្លួន។ ហេតុនេះ អំពើប្រល័យពូជសាសន៍មិនចាំបាច់ត្រូវកម្រិតនៅត្រឹមតែក្រុមជាតិពិន្ទុ ឬក្រុមពូជសាសន៍ប៉ុណ្ណោះទេ។

20. ទោះបីជាអង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក បានបញ្ជាក់យ៉ាងច្បាស់ថា សមាជិកនៃអង្គការប្រដាប់អាវុធ មិនមានលក្ខណៈសម្បត្តិជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក យ៉ាងណាក៏ដោយ ក៏អង្គហេតុដែលថា ការដកហូតសិទ្ធិរស់រានមានជីវិត គឺមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៅក្នុងករណីនេះ គួរតែជាអង្គហេតុដែលជម្នះលើឧបសគ្គនីតិវិធីនេះ ប្រសិនបើ ក.ស.ច.ស យល់ឃើញថា មាត្រា ៣ រួម មិនអនុវត្តចំពោះឃាតរបស់ ក.ប.ក ដែលបានទម្លាប់អាវុធ ហើយត្រូវមេបញ្ជារបស់ខ្លួនដកចេញពីបរិយាកាសសង្គ្រាម។

## សេចក្តីសន្និដ្ឋាន

21. ដោយផ្អែកលើច្បាប់នៅពេលនោះ គឺអាចថា ការវាយប្រហាររបស់រដ្ឋ ឬអង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធខ្លួនឯង អាចខុសច្បាប់តាមច្បាប់មនុស្សធម៌អន្តរជាតិ ដោយពិនិត្យឃើញថាការវាយប្រហារបែបនេះមិនបានសំដៅលើគោលដៅយោធាសមស្របទេ ប៉ុន្តែបែរជាសំដៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធទៅវិញ។

22. ជាងនេះទៀត តាមច្បាប់ទម្លាប់សិទ្ធិមនុស្សអន្តរជាតិ ការដកហូតសិទ្ធិរស់រានមានជីវិត អាចជាការរំលោភបំពាន។ វាជាអំពើប្រល័យពូជសាសន៍ប្រសិនបើក្រុមជាក់លាក់ណាមួយគឺជាគោលដៅនៃការវាយប្រហារក្នុងបំណងកម្ទេចបំផ្លិចបំផ្លាញក្រុមនោះ បើមិនអញ្ចឹងទេ វាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រសិនបើការវាយប្រហារនោះមានលក្ខណៈជាទូទៅ និងជាប្រព័ន្ធ។

23. ហេតុនេះ ក.ស.ច.ស គប្បីយល់ឃើញថា មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អាចអនុវត្តបាននៅក្នុងស្ថានភាពពិសេសនេះ ដោយពិនិត្យមើលភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងការប្រើប្រាស់ជាទូទៅ និងជាប្រព័ន្ធនូវវិធានការជាក់ស្តែងដែលបានដាក់គោលដៅវាយប្រហារបែបនោះ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦ | Catherine Moore | ទីក្រុង Baltimore រដ្ឋម៉ារីឡែន សហរដ្ឋអាមេរិក | *[ហត្ថលេខា]* |